មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៥-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៥៦ ស្ដីពីការតែងតាំងលោក **សាំង ខូនសុខ** ជាឧកញ៉ា ៧០៦

០៨-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៥៩ ស្ដីពីការផ្លាស់ប្ដូរតែងតាំង និងបែងចែកភារកិច្ចជូនឯកអគ្គរាជទូត ប្រចាំនៅបរទេស នូវ ឯកឧត្តម លោកជំទាវចំនួន ០៤ រូប ៧០៧

១២-៤-២០០៤ -Kret NS/KRT/0404/060 ELEVONS... ៧០៩

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦១ ស្ដីពីការតែងតាំងលោកជំទាវបណ្ឌិត **សឿង រដ្ឋចាវី** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៧១០

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦២ ស្ដីពីការតែងតាំងឯកឧត្តម **ហ៊ុយ សេដ្ឋ** ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានឋានៈស្មើ **អគ្គនាយក** ៧១១

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៣ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ប្យុងហាក់** (KIM BYOUNG HAK) សញ្ជាតិដើមកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៧១២

២០-៤-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៤ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី យ៉ុងណាំ** (LEE YONG NAM) សញ្ជាតិដើមកូរ៉េ កើតនៅខេត្ត Iksan សាធារណរដ្ឋកូរ៉េ ៧១៣

៣០-៤-២០០៤ ព្រះរាជក្រឹត្យ នស/រកត/០៤០៤/០៦៨ ស្ដីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **លូ គីមឈន់** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៧១៤

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៦-៤-២០០៤ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្ដីពីការប្រែក្លាយវិទ្យាស្ថានគ្រប់គ្រង ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង ៧១៥

២៨-៤-២០០៤ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្ដីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទបេងមាលា ៧១៨

៣០-៤-២០០៤ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្ដីពីការទទួលស្គាល់សាកលវិទ្យាល័យខេមរៈ ៧២៣

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព ៧២៦

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៨ អនក្រ.បក ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧២៧

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២១៩ អនក្រ.បក ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៧២៨

១៦-៤-២០០៤ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧២៩
២៧-៤-២០០៤ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៣០
២៧-៤-២០០៤ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣១
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣២
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៣
២៨-៤-២០០៤ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៤
២៩-៤-២០០៤ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤២
៣០-៤-២០០៤ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៤

២.សេចក្តីសំរេច

១៩-៤-២០០៤ -សេចក្តីសំរេចលេខ ២០ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧៤៥
២០-៤-២០០៤ -សេចក្តីសំរេចលេខ ២១ សសរ ស្តីពីការបង្កើតក្រុមការងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំលើកទី ២ រវាងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ៧៤៦
២៥-៤-២០០៤ -សេចក្តីសំរេចលេខ ២២ សសរ ស្តីពីការផ្ទេរសិទ្ធិការងារ ៧៤៨
២៦-៤-២០០៤ -សេចក្តីសំរេចលេខ ២៣ សសរ ស្តីពីការបង្កើតគណៈកម្មការ សម្របសម្រួល និងគ្រប់គ្រងគំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត ៧៤៩

III.ភារៈរបស់ក្រសួង

ធនាគារជាតិនៃកម្ពុជា

២៩-៤-២០០៤ -ប្រកាសលេខ ធ ៦.០៤-០៦២ ប្រក ស្តីពី រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ៧៥០

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក **តាំង ទួនសុង**

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤
ទូលថ្វាយបរមនាម និង ឡាយព្រះហស្តលេខា
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

រកល.០៤.០៤.០៥៦ លេខ: ៤៧ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាវី តាន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៥៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានផ្លាស់ប្តូរតែងតាំង និងបែងចែកភារកិច្ច ជូនឯកអគ្គរាជទូត ប្រចាំនៅបរទេស នូវឯកឧត្តម លោកជំទាវ ចំនួន ០៤ រូប ដែលមានរាយនាមដូចខាងក្រោម:

១-តែងតាំង លោកជំទាវ **ស៊ុន សារឿន** បច្ចុប្បន្នអនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា អមសហភាពអឺរ៉ុប ព្រមទាំងប្រចាំប្រទេសប៊ែលហ្ស៊ិក អូទ្រីស ហូឡង់ និងលុចហ្សំបួរ ដែលមានទីលំនៅស្ថានទៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក ។

២-តែងតាំង ឯកឧត្តម **ហោ ណាំបូរ៉ា** បច្ចុប្បន្នឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងញូវែលហ្សេឡង់ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំចក្រភពអង់គ្លេស និងជាឯកអគ្គរាជទូតតែងតាំង ប្រចាំប្រទេសដាណឺម៉ាក ហ្វាំងឡង់ ន័រវែស និងស៊ុយអែត ដែលមានទីលំនៅស្ថានទូតនៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ។

៣-តែងតាំង ឯកឧត្តម **អ៊ុច គឹមអន** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង និងជាឯកអគ្គរាជទូតតែងតាំង ប្រចាំប្រទេសអេស្ប៉ាញ អ៊ីតាលី និងលុចសំបួ ដែលមានទីលំនៅស្ថានទូតនៅទីក្រុងប៉ារីស ប្រទេសបារាំង ។

៤-តែងតាំង ឯកឧត្តម **មាស គឹមហេង** បច្ចុប្បន្នអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងញូវែលហ្សេឡង់ ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស.០៤.០៤.០៥៩

លេខ ៤៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មេសា ឆ្នាំ២០០៤

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ណាឌី តាន់

KRET

(Palais Royal)

NS/KRT/0404/060

NOUS
NORODOM SIHANOUK
ROI DU CAMBODGE

ELEVONS

I- Au rang de Ministre :

1- Son Excellence Monsieur KUY SOPHAL
2- Son Excellence Monsieur CHUM NGOEUN
3- Son Excellence Monsieur MEAK SAMPHUON

II- Au rang de Secrétaire d'Etat :

1- Son Excellence Monsieur CHHEA HORN
2- Son Excellence Monsieur AN SEAM
3- Son Excellence Monsieur UM EM

III- Au rang de Sous Secrétaire d'Etat :

1- Son Excellence Monsieur SO SINUON

IV- Au rang d'Ambassadeur :

1- Son Excellence Monsieur KEM SIEA
2- Son Excellence Monsieur LAC KY
3- Son Excellence Monsieur PHENG PHIRUN
4- Son Excellence Monsieur VANN VAN
5- Son Excellence Monsieur MEAS REN
6- Son Excellence Monsieur CHHENG HUOT
7- Son Excellence Monsieur YOU SAM EL

V- Au rang de Ministre - Conseiller :

1- Madame HANG SOKAN
2- Madame TAN SOKHA
3- Monsieur NEP CHANREASMEY
4- Monsieur NUON VANNAK
5- Monsieur TAN POK
6- Monsieur MEN VUTHY
7- Monsieur YIM VINAVUTH
8- Monsieur HY SAMAN
9- Monsieur BAN NON

VI- Au rang de Premier Secrétaire d'Ambassade :

1- Madame SOK KAN
2- Madame KHLOT RASMEY
3 Madame THAN RACHANA
4- Monsieur HO DINO

Fait le 12 Avril 2004

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ:០០១/០៤ [illegible]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៤

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ហត្ថលេខា

គង់ សំអុល

លេខ: ៤៥ [illegible]

[illegible]ដើម្បីចម្លងចែក

[illegible]ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ពរល.04.04.060

បានប្រថាប់ព្រះរាជលញ្ឆករួចហើយ

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងលោកជំទាវបណ្ឌិត **សឿង ឆ្លូងាទី** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរាជការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ការ.០៤.០៤.០៦១ ចំលងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឃុយ សេដ្ឋ ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤.០៤.០៤.០៦៧ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ (មេសា) ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/១៦៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត ឋិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក គីម ប៊្យុងហាក់ (KIM BYOUNG HAK) សញ្ជាតិដើមកូរ៉េ កើតថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៥៦ នៅ ខ័ណ្ឌ GURO ក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ៤៦.ចល

៣៧៤.០៤.០៤.១៦៣ ...ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី យ៉ុងណាំ** (LEE YONG NAM) សញ្ជាតិដើមកូរ៉េ កើតថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៥៥ នៅខេត្ត Iksan សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

កល. ០៤.០៤.៦៤

លេខៈ ៤៥ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ងី តាយី

ព្រះរាជក្រឹត្យ

នស/រកត/០៤០៤/០៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ត្រាស់ព្រះរាជទាន

ចំពោះ

ឯ.ឧត្តម លូ គឹមឈន់

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជក្រឡាបន្ទូល

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរស.០៤០៤.០៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រែក្លាយវិទ្យាស្ថានជាតិគ្រប់គ្រង ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

បានឃើញសេចក្តីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រង និងការបើកថ្នាក់បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ : ប្រែក្លាយ វិទ្យាស្ថានជាតិគ្រប់គ្រង ទៅជា សាកលវិទ្យាល័យជាតិគ្រប់គ្រង "NATIONAL UNIVERSITY OF MANAGEMENT" ហៅកាត់ជាភាសាខ្មែរ "ស.ជ.គ" និងហៅកាត់ជាភាសាអង់គ្លេស "NUM" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ : សាកលវិទ្យាល័យជាតិគ្រប់គ្រង មានតួនាទីជា មជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ថែរក្សានិងលើកស្ទួយនូវអត្តសញ្ញាណជាតិ ។

មាត្រា ៣ : សាកលវិទ្យាល័យជាតិគ្រប់គ្រង ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- ថ្នាក់បណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៣ ឆ្នាំ

មាត្រា ៤ : សាកលវិទ្យាល័យជាតិគ្រប់គ្រង មាន ៦ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យគ្រប់គ្រង
២. មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យ
៣. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច
៤. មហាវិទ្យាល័យសេដ្ឋកិច្ច
៥. មហាវិទ្យាល័យនីតិសាស្ត្រ
៦ មហាវិទ្យាល័យព័ត៌មានវិទ្យា
និង ថ្នាក់ក្រោយបរិញ្ញាប័ត្រ ។

សាកលវិទ្យាល័យនេះ មានសាខាមួយ ស្ថិតនៅទីរួមខេត្តបាត់ដំបង ។ ទៅអនាគត សាកលវិទ្យាល័យជាតិគ្រប់គ្រង អាចបើកសាខា មហាវិទ្យាល័យ ឯកទេស ក៏វិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៦ : សាកលវិទ្យាល័យជាតិគ្រប់គ្រង ដឹកនាំដោយ សាកលវិទ្យាធិការមួយរូប ដែលមានការតែងតាំងដោយព្រះរាជក្រឹត្យ និងមានសាកលវិទ្យាធិការរង ជាជំនួយការ តាមតម្រូវការចាំបាច់ ដែលតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ៧ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
  "ដើម្បីមុខការ"
- ដូចមាត្រា ៨
  "ដើម្បីអនុវត្ត"

កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់មណ្ឌលីយដ្ឋានប្រាសាទបេងមាលា

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ [illegible] ៩៤ ចុះថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី [illegible]១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

បានឃើញព្រះរាជក្រឹត្យលេខ ០០១ [illegible] ចុះថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ១៩៩៤ ស្តីពី [illegible] ចំពោះ [illegible] អង្គរ

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/[illegible] ចុះថ្ងៃទី [illegible] ឆ្នាំ ១៩៩៥ ស្តីពីការ [illegible] [illegible]

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ " អប្សរា "

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើតអាជ្ញាធរ " អប្សរា "

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤

សំរេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

តំបន់រមណីយដ្ឋានប្រាសាទបេងមាលា ជាតំបន់ការពារស្ថិតនៅក្នុងភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ផ្អែកទៅតាមព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពី[illegible] និងការ[illegible]គ្រប់គ្រងតំបន់សៀមរាប អង្គរ ។

មាត្រា ២.-

អនុក្រឹត្យនេះមានបំណង :

អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិសាស្ត្រ និងលើកតម្កើងតម្លៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត

អភិរក្សទេសភាព វប្បធម៌ និងអភិវឌ្ឍតំបន់ទេសចរណ៍

ការពារបរិស្ថានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង និងអនុវត្តតាមគោលការណ៍នានា [illegible] និងបទប្បញ្ញត្តិដែលជាធរមាន ។

ជំពូកទី ២

ការកំណត់តំបន់

មាត្រា ៣.

[illegible]

មាត្រា ៤.-

រមណីយដ្ឋានការពារប្រាសាទបេងមាលា កំណត់ជាពីរតំបន់ផ្សេងគ្នា ដូចមានផែនទីក្នុងឧបសម្ព័ន្ធទី ១ ហើយត្រូវទទួលកិច្ចការពារខុសៗគ្នា ៖

ក.តំបន់ ១ ៖ រមណីយដ្ឋានមានប្រាសាទ គឺជាតំបន់ដែលមានស្ថានីយបុរាណវត្ថុសំខាន់ៗជាងគេ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។ តំបន់នេះ មានចម្ងាយប្រវែង១៥០ (មួយរយហាសិបម៉ែត្រ) ពីកំពែងប្រាសាទក្រៅបំផុត ដល់ខ្សែបន្ទាត់និយាមកានៃចំណុចដូចតទៅ ៖

A0 (416680 , 1489350)	,	A6 (419150 , 1489550)
A1 (416140 , 149[illegible]400)	,	A7 (418360 , 1489520)
A2 (41726[illegible] , 14904[illegible]0)	,	A8 (417570 , 1489500)
A3 (417260 , 1490470)	,	A9 (4172[illegible] , 1489490)
A4 (419300 , 1490470)	,	A10 (417130 , 148936[illegible])
A5 (419300 , 14895[illegible])	,	A11 (416560 , 1489370)

តំបន់ទី ១នេះ មានផ្ទៃក្រឡា ៣១៥ ហិកតា ៣ (បីរយដប់ប្រាំហិកតា និងបីអារ)

ខ.តំបន់ ២ ៖ តំបន់ការពារបុរាណវត្ថុត្រូវការពារ គឺតំបន់ដែលសម្បូរសំណល់បុរាណវត្ថុដែលត្រូវការពារទប់ទល់នឹងការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍន៍មិនសមស្រប និងត្រូវមានការវាយតម្លៃផលប៉ះពាល់ដល់បរិស្ថាន ។ តំបន់នេះមានចម្ងាយប្រវែង ២៥០ (ពីររយហាសិបម៉ែត្រ) ពីខ្សែបន្ទាត់និយាមកា A0 [illegible] A11 ដល់ខ្សែបន្ទាត់និយាមកានៃចំណុច[illegible]ទៅ ៖

B[illegible] (4[illegible] , [illegible])		B4 (419350 , [illegible])
B1 (41[illegible] , 14[illegible])	,	B5 (419550 , 148931[illegible])
B2 (4170[illegible] , 1[illegible])		B6 (417350 , 148925[illegible])
B3 (417030 , 1[illegible])		B7 (417300 , [illegible]48912[illegible])

តំបន់ទី ២ នេះមានផ្ទៃក្រឡា ២៤១ ហិកតា ៦ (ពីររយសែសិបមួយហិកតា និងប្រាំមួយអារ)

ចំពោះតំបន់ទី ៣ តំបន់ទី ៤ និងតំបន់ទី ៥ កិច្ចការពារមានចែងនៅក្នុងព្រះរាជក្រឹត្យលេខ [illegible] ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្ដីពីការកំណត់ និងការគ្រប់គ្រងតំបន់សៀមរាបអង្គរ ។

ជំពូកទី ៣

ការរក្សាតំបន់

មាត្រា ៥.-

[illegible]ត្រូវតែ[illegible] និង [illegible]ស្របតាមទិសដៅសំរាប់តំបន់[illegible] [illegible] ។ [illegible] [illegible]ដ្ឋាន[illegible] [illegible] [illegible] ហើយ[illegible] [illegible] [illegible] ។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

មាត្រា ៦.-

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សាកលវិទ្យាល័យខេមរៈ

****

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រម ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

បានឃើញលិខិតរបស់លោក ទួ ចាន់សុភិ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤

តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យខេមរៈ Khemarak University ហៅកាត់ជាភាសាខ្មែរ "ស.ខ." និងហៅកាត់ជាភាសាអង់គ្លេស "K.U."។

សាកលវិទ្យាល័យខេមរៈ មានទីតាំងស្ថិតនៅអាគារប្រផេះ មហាវិថីព្រះសីហនុ (២៧៤) កែងទីងផ្លូវ សម្ដេចសុធារស (៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យខេមរៈ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យខេមរៈ ធ្វើការបណ្ដុះបណ្ដាលថ្នាក់ :

- បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ

បណ្ឌិតសិក្សាស្រាវជ្រាវរយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សាកលវិទ្យាល័យខេមរៈត្រូវរៀបចំកម្មវិធីសិក្សាលំអិតដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យខេមរៈ មាន ៧ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ
២. មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
៣. មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និង ទំនាក់ទំនងអន្តរជាតិ
៤. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
៥. មហាវិទ្យាល័យមនុស្សសាស្ត្រ សិល្បៈ និងភាសាវិទ្យា
៦. មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ
៧. មហាវិទ្យាល័យវិទ្យាសាស្ត្របច្ចេកវិទ្យា និងព័ត៌មានវិទ្យា

និង មានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងស្រាវជ្រាវមួយ ។

នៅអនាគត សាកលវិទ្យាល័យខេមរៈ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្ដុះបណ្ដាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : សាកលវិទ្យាល័យខេមរៈ មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និងក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រមួយ សំរាប់អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងល័ក្ខខ័ណ្ឌទទួលនិស្សិតអោយចូលរៀន សាកលវិទ្យាល័យខេមរៈត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីការទទួលនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថាន ឧត្តមសិក្សា ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យខេមរៈ មានភារកិច្ច :

ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ។

ជ្រើសរើសសិស្ស និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។

គ្រប់គ្រងអោយបានល្អនូវការងារសិក្សា ការងារស្រាវជ្រាវ ការប្រឡង និងការប្រគល់សញ្ញាប័ត្រ ។

គោរព និងអនុវត្តតាម បទដ្ឋានរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។

ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។

ធ្វើរបាយការណ៍ពីសកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យខេមរៈ និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យខេមរៈ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យខេមរៈ មានភារកិច្ចអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងខេត្ត
- "ដើម្បីជូនដំណឹង"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧១១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៦/០៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស រកត/០២០០/១០៩ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ តត ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងអភិបាលរងខេត្ត ក្រុង
- យោងសេចក្តីចម្លងសំបុត្រមរណភាពរបស់លោក **ឈឹម ឆាម** លេខ ០១ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានលុបឈ្មោះលោក **ឈឹម ឆាម** អភិបាលរងទី ១ ខេត្តស្វាយរៀង ដែលបានទទួលមរណភាពកាលពីថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៤ ដោយមរណភាព ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ ឯកសារ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ពានជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ពានជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងរូបសំណាក លោកតាដំបងក្រញូង ឧបត្ថម្ភអង្ករ សារុង ទឹកស៊ីអ៊ីវ និង ថវិកា ប្រគេនព្រះសង្ឃ និង ជូនប្រជាពលរដ្ឋ នៅក្នុងស្រុកបាត់ដំបង ស្រុកឯកភ្នំ និង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ៖

១ លោក **ខ្វាន់ សារ៉េត** និង អ្នកស្រី **សោ គឹមឈួ** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣២ ០០០ ដុល្លារ
២ លោក **ចំនួ សុវណ្ណរិទ្ធ** ហៅគ្រាក្លុង នៅខេត្តបាត់ដំបង ថវិកា ចំនួន ១២.៦៤០ ដុល្លារ

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/ ✓

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល ៖
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និងមាត្រា២
រាជកិច្ច ✓
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២៧ អនក.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងកុដិ ០១ខ្នង មាន ១២ បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម និង កុំព្យូទ័រ ចំនួន ០៣គ្រឿង នៅក្នុងវត្តមហាមន្ត្រី សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :

១	ព្រះតេជគុណ	**ខុំ ស៊ីម៉ាប់**	ទីប្រឹក្សាសម្តេចព្រះសង្ឃរាជ ទេព វង្ស និង ជាប្រធានសាងសង់ វត្តមហាមន្ត្រី បច្ច័យ ចំនួន ២១ ០៤៣ ដុល្លារ	
២	លោកស្រី	**ខៀវ ចន្ថា**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១២ ៤៥០ ដុល្លារ
៣	លោក	**សាន សម្ភារៈ**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១០ ៣៥៩ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយបានមានប្រសិទ្ធផលល្អ ១៤ ៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧ ០៧ (,ថ៍ស(ក ឥភ

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៩ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ចាម

ស ម្រេ ច

មាត្រា ១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកតាព្រឹទ្ធាចារ្យ **ចាយ គឹមហុង** ហៅ លោកគ្រូ **ខាម ខ្មុយ** ដែលមានស្នាដៃល្អ ក្នុងការថែរក្សាបេតិកភណ្ឌវប្បធម៌ និង ការពារទំនៀមទំលាប់ប្រពៃណីជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និង មាត្រា២
រាជកិច្ច ,
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ក្រសួងសុខាភិបាល

សម្រេច

មាត្រា១ ត្រូវបានតែងតាំងលោកស្រីវេជ្ជបណ្ឌិត **យក់ សម្បត្តិ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល។

មាត្រា២ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- [illegible]
- ដូចមាត្រា២
- [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ហាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានប្រគល់ **មេដាយមាសស្ហាបនាជាតិ** ចំនួន ០៤ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៤រូប ដែលបាន បរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងព្រះវិហារ វត្តចំប៉ាចាស់ ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមាន រាយព្រះនាម និង នាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **ជ័យ ផន**	ព្រះចៅអធិការវត្តចំប៉ាចាស់	បច្ច័យចំនួន	១១.៣០០ ដុល្លារ
២ ព្រះតេជគុណ **សួន ស៊ីខួន**	គង់នៅប្រទេសអូស្ត្រាលី	បច្ច័យចំនួន	១០.២០០ ដុល្លារ
៣-លោកស្រី **នី ស្រី** និង អ្នកស្រី **ញ៉ឹម ឡៃ**	នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	១៥.៥៥០ ដុល្លារ
៤ ឧបាសិកា **អួន**	នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	១១.៥០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា ១៩៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក **ខិត ពិជ័យ** សប្បុរសជនខ្មែរ នៅប្រទេសជប៉ុន ដែលបានបរិច្ចាគ ធនធាន ជួយកសាងសមិទ្ធផលនានា ក្នុងវិស័យអប់រំ និង វិស័យធម្មទានមទី នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ចំណាយថវិកាអស់ចំនួន ១០២.២៥០ ដុល្លារ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និង មាត្រា២
រាជកិច្ច ,
ឯកសារ កាលប្បវត្តិ

រាជធានីភ្នំពេញ . ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលនានា ក្នុងវិស័យអប់រំ និងវិស័យគមនាគមន៍ នៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដូចមានរាយនាមខាងក្រោម ៖

១-អ្នកស្រី	**ឌុន សឿន**	សប្បុរសជនខ្មែរនៅជប៉ុន	ថវិកាចំនួន ១០.៥០០ ដុល្លារ
២-លោក	**ទិត សុផាន**	សប្បុរសជនខ្មែរនៅជប៉ុន	ថវិកាចំនួន ១០.៥០០ ដុល្លារ
៣ លោក	**NAGA SATORU**	សប្បុរសជនជប៉ុន	ថវិកាចំនួន ១០.២០០ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និង មាត្រា២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤.៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

សំរេច

មាត្រា ១ :ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី និយោជិត កម្មករ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចំនួន ១៩៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនកំពង់ផែ ៣ ឆ្នាំ ២០០៣កន្លងមក ដូចមានរាយនាមខាងក្រោម

ក.មេដាយមាសការងារ :

១	លោក	**សរ សត្យា**	ប្រធានផ្នែកការពារទេសចរផែស្ងួត CWT
២	លោក	**ទន្ទី សំអាង**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៣	លោក	**សារ៉ា ប៊ុំ វណ្ណា**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៤-	លោក	**ពិត ច្រាកដ**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៥	លោក	**អ៊ិច ឥន្ទបុត្រា**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៦	លោក	**រ៉ឺន ចាន់**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៧	លោក	**ឆរី ជឹន**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
៨	លោក	**យ៉ុន យ៉ឹប**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
៩	លោក	**តុច ស៊ីផល**	មន្ត្រីនាយកដ្ឋានបច្ចេកទេស

១០	លោក	**សម សុភាព**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
១១	លោក	**គឹម ឃាន**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
១២-	លោក	**ចេន សុខី**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
១៣-	លោក	**កៅ សារឿន**	មន្ត្រីនាយកដ្ឋានផែនការ ស្ថិតិ
១៤	លោក	**យូ ឡេង**	មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា
១៥	លោក	**ហេង សុខសាន្ត**	មន្ត្រីនាយកដ្ឋានទីផ្សារ
១៦	លោក	**ហ៊ុន សំណាង**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៧-	លោក	**ហ៊ុ ហែមចន្ទ**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ

ខ. មេដាយប្រាក់ការងារ :

១	លោក	**ឆេត គឹមអឿន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
២-	លោកស្រី	**សោម ជី**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៣-	លោក	**សុខ ចិត្រា**	មន្ត្រីនាយកដ្ឋានផែនការ ស្ថិតិ
៤	លោក	**ឃុន សុខន**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
៥	លោក	**សេង ប៊ុនថន**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
៦-	លោក	**ស៊ុ សុខា**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
៧	លោក	**គង់ សុភា**	មន្ត្រីនាយកដ្ឋានទីផ្សារ
៨	លោក	**ចាន់ គាំង**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
៩	លោក	**ជា ចាន់ថន**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
១០	លោក	**សោម សុខុម**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
១១	លោក	**ឈឿន ឡុងឌី**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
១២	លោក	**គាង ហុង**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៣	លោក	**ស្រេង ប៊ុនឆាង**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៤	លោក	**គឹម ហេង**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៥	លោក	**ស៊ូ សុផល**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៦	លោក	**ពុធ ហេង**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៧	លោក	**ជ័រ ពិដោរ**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៨	លោក	**កុយ ទិសាល**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
១៩	លោក	**មិន សីហា**	មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដធារ
២០	លោក	**ស៊ីង សារ៉ម**	មន្ត្រីនា[illegible]

២១- លោក ម៉ី ម៉ានី មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២២ លោក លី ខួន មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៣ លោក អ៊ុក សុវណ្ណារិទ្ធិ មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៤- លោក កែវ សុវណ្ណ មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៥ លោក ញ៉ឹម ចាន់ឫទ្ធី មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៦ លោក កាន់ ដារិន មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៧- លោ.ក អ៊ុម សុផល មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៨ លោក ឌិត សុផល មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

២៩ លោក សយ សំអុល មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

៣០- លោក ម៉ុល ឈឹម មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣១ លោក ដួង សារ៉ិន មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣២ លោក ហុង សុវណ្ណ មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣៣- លោក ឯម ហាន មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣៤ លោក ពេជ្រ សឿន មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣៥- លោក ស្រី គន្ធារ មន្ត្រីនាយកដ្ឋានគ្រឿងចក្រ ដឹកជញ្ជូន

៣៦- លោក កែវ ចិន្ដា មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៣៧- លោក ហេង លាងកាង មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៣៨- លោក គង សុត មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៣៩ លោក ឈុប សុផល មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៤០ លោក សាយ សុជឿន មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៤១- លោក ប្រាក់ ចន្ទ័ស្មី មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា

៤២ លោក យ៉េង គីមអាន មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក

៤៣- លោក គីម ម៉ើ មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក

៤៤ លោកស្រី តិន សុវណ្ណា មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក

៤៥ លោក ស៊ឹម ញ៉ឹម មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក

៤៦ លោក រឹម ចាន់ថូ មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក

៤៧ លោក នូ រ៉ាដា មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក

គ-មេដាយសំរិទ្ធការងារ :

១	លោក **រឹម មិន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
២-	លោក **គុល ឆលុប**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៣	លោកស្រី **លី ហុង**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៤	លោក **ឌូ ហៀន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
៥	លោក **ហ៊ិន ឡៀន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៦	លោក **លាង គីមសេង**	មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
៧-	លោក **ស៊ី យ៉ឹម**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៨	លោក **កែវ សារ៉ិន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
៩	លោក **ម៉ើន សុផាត**	មន្ត្រីនាយកដ្ឋានរដ្ឋបាល-បុគ្គលិក
១០	លោក **សួន ម៉ារី**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
១១	លោក **ជ័យ ទេវ្ធា**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
១២	លោកស្រី **សេង សុផា**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
១៣	លោកស្រី **ជា សារទេន**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
១៤-	លោកស្រី **ឈួន ឈារ៉ាត់**	មន្ត្រីនាយកដ្ឋានរដ្ឋបាល បុគ្គលិក
១៥	លោក **ឆុំ សាត**	មន្ត្រីនាយកដ្ឋានផែនការ ស្ថិតិ
១៦-	លោក **ឃុន វិចិត្រ**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
១៧	លោក **ថោង សាំង**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
១៨	លោក **ខួន រតនា**	មន្ត្រីនាយកដ្ឋានកិច្ចការជំនួញ
១៩-	លោក **អ៊ុក រតនៈ**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
២០	លោក **នួន ផល្លី**	មន្ត្រីនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
២១-	លោកស្រី **ឈឹម ដារ៉ី**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
២២	លោកស្រី **ដួង ផារ៉ាទ័ន**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
២៣	លោក **គង់ ជាស**	មន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
២៤	លោក **មាស សុវណ្ណា**	មន្ត្រីនាយកដ្ឋានទីផ្សារ
២៥	លោក **ឃី ហាឈាន់**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
២៦	លោក **សេង រតនា**	មន្ត្រីនាយកដ្ឋានបច្ចេកទេស
២៧	លោក **នួន នាំសុជាតិ**	មន្ត្រីនាយកដ្ឋានបច្ចេកទេស

២៨ លោក **ម៉ឺន សុខេង** មន្ត្រីនាយកដ្ឋានបច្ចេកទេស

២៩ លោក **ជា អៀម** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣០- លោក **មឹម កុសល** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣១ លោក **ហុង សុធី** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣២ លោក **ជា ឃុន្នី** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៣ លោកស្រី **សរ ម៉ាលីន** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៤ លោក **អន សារ៉ាវឌិត** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៥- លោក **ឌុំ សុផារ** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៦ លោក **ឈឹម ហ៊ឹរ** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៧- លោក **សំ សុផា** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៨ លោក **ឈន ទឹម** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៣៩- លោក **អ៊ុយ អៀង** មន្ត្រីនាយកដ្ឋានបច្ចេកទេស

៤០ លោក **ចេង ទី** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤១ លោក **ស៊ិន មុន្នីវណ្ណ** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤២ លោក **ឈុត ចរិន្ទី** មន្ត្រីនាយកដ្ឋាននាវាចរ-កណ្ដារ

៤៣ លោក **អ៊ី ស៊ីណារុន** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៤ លោក **តាំង ខួន** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៥- លោក **ជីង ឈួង** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៦ លោក **សំ ហោត** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៧- លោក **ជ្រួន ស៊ីវ** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៨ លោក **មៀង ណារ៉ា** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៤៩- លោក **នី សុខលាង** មន្ត្រីនាយកដ្ឋាននាវាចរ កណ្ដារ

៥០ លោក **ប៉ែម សារៈមិត** មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

៥១ លោក **សេង ពៅស្រស់** មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

៥២ លោក **ខេង សាយ** មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

៥៣ លោក **ស៊ូ សេង** មន្ត្រីនាយកដ្ឋានលើកដាក់ទំនិញ

៥៤ លោក **ណាង ជា** កម្មករកងបច្ចេកទេសលើកដាក់

៥៥ លោក **គុល ឡក** កម្មករកងបច្ចេកទេសលើកដាក់

៥៦ លោក **នេង សំអ៊ាន** កម្មករកងបច្ចេកទេសលើកដាក់

៥៧	លោក	រស់ ថុយ	កម្មករកងបច្ចេកទេសលើកដាក់
៥៨	លោក	ទេវ គឹមស៊ុន	កម្មករកងបច្ចេកទេសលើកដាក់
៥៩	លោក	សំ សុផាន់	កម្មករកងបច្ចេកទេសលើកដាក់
៦០ -	លោក	ភឹល ញ៉ាក់	កម្មករកងបច្ចេកទេសលើកដាក់
៦១	លោក	ឆេន ឈរាប	កម្មករកងបច្ចេកទេសលើកដាក់
៦២	លោក	គឹម សុផល	កម្មករកងបច្ចេកទេសលើកដាក់
៦៣ -	លោក	សាំង ហ៊ុន	កម្មករកងបច្ចេកទេសលើកដាក់
៦៤	លោក	អ៊ុក ចន្ថា	កម្មករកងទី ១
៦៥ -	លោក	ទៅ ខាន់	កម្មករកងទី ១
៦៦	លោក	ចក់ ហៀង	កម្មករកងទី ១
៦៧ -	លោក	ប៉ើន ខាត	កម្មករកងទី ២
៦៨	លោក	សួស សន	កម្មករកងទី ២
៦៩	លោក	សៀន សុខ	កម្មករកងទី ២
៧០	លោក	ម៉ុំ ទី	កម្មករកងទី ៣
៧១ -	លោក	កៀត សំអុល	កម្មករកងទី ៣
៧២	លោក	សួន គឹម	កម្មករកងទី ៣
៧៣	លោក	ជាតិ ខន	កម្មករកងទី ៤
៧៤	លោក	ខួន សំបាត់	កម្មករកងទី ៤
៧៥ -	លោក	ចាប់ សុខុន	កម្មករកងទី ៤
៧៦	លោក	សំ មន	កម្មករកងទី ៥
៧៧ -	លោក	ជ័រ នួច	កម្មករកងទី ៥
៧៨	លោក	ម៉ក់ គឹម	កម្មករកងទី ៥
៧៩ -	លោក	ចាន់ ឧត្តម	កម្មករកងទី ៦
៨០ -	លោក	ប្រាក់ ខែម	កម្មករកងទី ៦
៨១	លោក	ជុំ សុផាត	កម្មករកងទី ៦
៨២	លោក	តិន សឿន	កម្មករកងទី ៧
៨៣	លោក	គុយ ចែម	កម្មករកងទី ៧
៨៤	លោក	ហាក់ សឿន	កម្មករកងទី ៨
៨៥	លោក	ផាន់ ឈួន	កម្មករកងទី ៨

៨៦	លោក ប្រាជ សុផល	កម្មករកងទី ៨
៨៧	លោក ឈឹម សែម	កម្មករនាយកដ្ឋានលើកដាក់ទំនិញ
៨៨	លោក ញឿម មុយ	កម្មករនាយកដ្ឋានលើកដាក់ទំនិញ
៨៩ -	លោក តូច ប៊ុន	កម្មករនាយកដ្ឋានលើកដាក់ទំនិញ
៩០ -	លោក សុខ ម៉េន	មន្ត្រីនាយកដ្ឋានគ្រឿងចក្រ-ដឹកជញ្ជូន
៩១ -	លោក អ៊ុក ប្រុច	កម្មកររថយន្តស្ទូច
៩២	លោក សោម នុច	កម្មកររថយន្តស្ទូច
៩៣ -	លោក នាង ម៉ែន	កម្មកររថយន្តស្ទូច
៩៤ -	លោក អ៊ុំ ផល	កម្មកររថយន្តស្ទូច
៩៥	លោក ជា ប៊ុនឡា	កម្មកររថយន្តស្ទូច
៩៦ -	លោក សាត ប៊ុនធឿន	កម្មកររថយន្ត
៩៦	លោក ឆន ស៊ឹម	កម្មកររថយន្ត
៩៨	លោក មួន ទិន	កម្មកររថយន្ត
៩៩ -	លោក ស៊ុម សំអឿន	កម្មកររថយន្ត
១០០-	លោក អ៊ុ ម៊ីន	កម្មកររថយន្ត
១០១	លោក ម៉ឺន នួច	កម្មកររថយន្តជួតឹកហ្វ៊ែម
១០២	លោក ម៉ុស ផន	កម្មកររថយន្តជួតឹកហ្វ៊ែម
១០៣	លោក សាត សុខាមុន្នី	កម្មកររថយន្តជួតឹកហ្វ៊ែម
១០៤-	លោក ខិន កែប	កម្មកររថយន្តធូក
១០៥	លោក ណុប ផាត	កម្មកររថយន្តធូក
១០៦	លោក ធិត សារឿន	កម្មកររថយន្តធូក
១០៧-	លោក ហេង ម៉ុងហ៊ត	កម្មករបើកបរគ្រឿងចក្រធុនធ្ងន់
១០៨	លោក មួល ប៊ុណ្ណារត្ន័	កម្មករបើកបរគ្រឿងចក្រធុនធ្ងន់
១០៩	លោកស្រី អ៊ុក ណារិន	មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា
១១០	លោក ហែម សំបូរ	មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា
១១១	លោក ចាន់ សារិទ្ធិ	មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា
១១២-	លោក ប៊ុម ពន្លឺសេដា	មន្ត្រីនាយកដ្ឋានឃ្លាំង ទីលាន កត់ត្រា
១១៣-	លោក សេក សុវណ្ណារ៉ា	កម្មករតឹរ រាជ ១
១១៤	លោក ឌឹម ចាន់មុន្នី	[illegible]

១១៥	លោក **នាង ខេមរា**	កម្មករទីលាន ១
១១៦-	លោក **ឃី សុវណ្ណ**	កម្មករទីលាន ១
១១៧	លោក **នួយ ចន្ទី**	កម្មករទីលាន ២
១១៨-	លោក **អ៊ុយ សារុន**	កម្មករទីលាន ២
១១៩-	លោក **យូ ឡេង**	កម្មករទីលាន ២
១២០-	លោក **ស្រី សាខន**	កម្មករទីលាន ២
១២១-	លោក **ហេង ហាក់**	កម្មករជញ្ជីង
១២២	លោក **សុខ ខុន**	កម្មករសំអាតផែ
១២៣	លោក **ម៉ើន រី**	កម្មករសំអាតផែ
១២៤-	លោក **ប្រាក់ សារិន**	កម្មករសំអាតផែ
១២៥	លោក **ហាច្ស មុំ**	កម្មករសំអាតផែ
១២៦	លោក **ហ៊ឹម សុភាព**	កម្មករសំអាតផែ
១២៧	លោក **ម៉ុង សាន**	កម្មករសំអាតផែ
១២៨	លោកស្រី **អ៊ីង តារាសុវណ្ណនា**	កម្មករសំអាតផែ
១២៩-	លោក **គាត ខុន**	កងការពារ
១៣០	លោក **ម៉ើន ម៉ុន**	កងការពារ
១៣១-	លោក **បិណ្ណា ប៊ុនធឿន**	កងការពារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ

ស ម្រ េ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ១២ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ១២រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ព្រះវិហារ កុដិ ក្រោង សាលាពុទ្ធិកៈ ព្រះពុទ្ធរូប ស្រះទឹក និង សមិទ្ធផលផ្សេងៗទៀត នៅក្នុងវត្តអនុវនារាម ហៅ វត្តព្រៃតូច ឃុំព្រៃតូច ព្រមទាំងជួយកសាងព្រះវិហារ វត្តជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និង នាម ខាងក្រោមនេះ :-

១-ព្រះតេជគុណ **អ៊ុង** **អុន** ព្រះចៅអធិការវត្តអនុវនារាម ហៅ វត្តព្រៃតូច បច្ច័យចំនួន ១០៦.៨៩៥ ដុល្លារ
២ លោក **ឆេង** **តេង** និង ភរិយាព្រមទាំងបុត្រ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣១.៦០០ ដុល្លារ
៣-ឯកឧត្តម **អ៊ុង** **សំខាន់** និង លោកជំទាវ ព្រមទាំងបុត្រ សប្បុរសជននៅក្រុងភ្នំពេញ ថវិកាចំនួន ១១.៥០០ ដុល្លារ
៤-លោក **ឆាំង** **ជុំជាង** និង ភរិយាព្រមទាំងបុត្រ សប្បុរសជន នៅខេត្តបាត់ដំបង ថវិកាចំនួន ១១.៧២៧ ដុល្លារ
៥-អ្នកស្រី **អ៊ឹម** **ឃុត** ព្រមទាំងបុត្រ សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៧០០ ដុល្លារ
៦ ឯកឧត្តម **ជា** **សុជាតិមង្គល** និង លោកជំទាវ សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១១.៥០០ ដុល្លារ
៧-លោក **ស៊ិន** **ជិន** និង ភរិយាព្រមទាំងបុត្រ សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៥០០ ដុល្លារ
៨-លោកតា ម៉ៅ រី និង លោកយាយព្រមទាំងបុត្រ សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៣០០ ដុល្លារ
៩ លោក **ឆាំង** **ឈួ** និង ភរិយាព្រមទាំងបុត្រ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១ ៣០០ ដុល្លារ

១០-លោក អ៊ុ ទឿង និង ភរិយា ព្រមទាំងបុត្រ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.១០០ ដុល្លារ

១១-លោក សោម ជុំ និង ភរិយា ព្រមទាំងបុត្រ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១ ០០០ ដុល្លារ

១២ លោក សិន គ្រី និង ភរិយា ព្រមទាំងបុត្រ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

173

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២២៧ អនក្រ.គស

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលជាគណៈប្រតិភូនៃតំបន់ស្វយ័ត GUANGXI ZHUANG សាធារណរដ្ឋប្រជាមានិតចិន ដែលបានជូនម៉ាស៊ីនបូមទឹកភ្ជាប់ជាមួយម៉ូទ័របូមទឹកម៉ាក KANG HAI កម្លាំងពី ៤ ទៅ ៥ សេស ចំនួន ១០០ គ្រឿង ជូនសម្តេចនាយករដ្ឋមន្ត្រី សំរាប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ដូចមានរាយនាមខាងក្រោមនេះ ÷

១ ឯកឧត្តម LU BING អភិបាលនៃតំបន់ស្វយ័ត GUANGXI ZHUANG , P.R.China.
២ លោក YU CHANGWEN ប្រធានសាជីវកម្មចិន GUANGXI សំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ បច្ចេកទេសវិទ្យាសេដ្ឋកិច្ច

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានបន្ទុក [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
[illegible]
[illegible]
[illegible]
[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦០ សសរ

សេចក្តីសម្រេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន និងចូលរួមសន្និសីទប្រចាំឆ្នាំអាស៊ី ២០០៤ នៃវេទិកាបូអាវ នៅខេត្ត ហៃ ណាន សាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧១ អនក្រ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំលើកទី២ របស់អភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ២៧៤ សចណផក របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៤
- យោងលិខិតលេខ ២០សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១ ៖ ត្រូវបានបង្កើតក្រុមការងាររបស់កម្ពុជា ដើម្បីរួមជាមួយក្រុមការងាររបស់ថៃ ដើម្បីរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា ថៃលើកទី២ ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម	**ញ៉ឹម សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	ប្រធាន
២-ឯកឧត្តម	**គឹយ ឿន**	អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាលកម្ពុជា	អនុប្រធាន
៣-លោក	**សក់ សេដ្ឋា**	អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ	សមាជិកអចិន្ត្រៃយ៍

៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ទៅ ចាន់តារា** អគ្គស្នងការរងនគរបាលជាតិ សមាជិក

៥ លោក **ផាន ឡេងហួត** អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

៦-លោកឧត្តមសេនីយ៍ **ឈុំ សុជាតិ** មេបញ្ជាការទីចាត់ការព្រំដែន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

៧ លោក **ហែម សារឹម** ប្រធាននាយកដ្ឋានអាស៊ីទី១ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-លោកឧត្តមសេនីយ៍ **ចាន់ អ៊ីវន** ប្រធាននាយកដ្ឋានព្រំដែនគោក អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

៩ លោកឧត្តមសេនីយ៍ **គៀត ចន្ទថរិទ្ធិ** ប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១០ លោកឧត្តមសេនីយ៍ **ឡៅ ស៊ុនឆៃ** ប្រធាននាយកដ្ឋានព្រំដែនទឹក អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១១-លោកវរសេនីយ៍ឯក **សុខ សារិត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

១២ លោក **ញាណ វិបុល** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

១៣ លោក **ខាំ ពុនកែវបុនី** អ្នកបកប្រែ

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ចពិភាក្សាសំរបសំរួលជាមួយក្រុមការងារថៃ ដើម្បីត្រៀមកិច្ចប្រជុំលើកទី១ រវាងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ឲ្យបានលទ្ធផលល្អប្រសើរ ។

ប្រការ ៣ : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម អស់លោក ដែលមានរៀបរាប់ក្នុងប្រការ១ ទទួលភារកិច្ចអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រីស្តីទី

ស ខេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : [illegible]

សេចក្តីសម្រេច

ស្តីពីការផ្ទេរសិទ្ធិការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **លី ធុជ** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសឯកឧត្តម **ឃឹម ឆាយលីប** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលត្រូវអញ្ជើញទៅចូលរួមសន្និបាតលើកទី ៦០ នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គម របស់ អសប សំរាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិច និងកិច្ចចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីប្រព័ន្ធផ្លូវអាស៊ានហៃវេ នៅទីក្រុងសៀងហៃ ប្រទេសចិន ចាប់ពីថ្ងៃទី ២៤ ខែ មេសា ដល់ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ រហូតដល់ពេលឯកឧត្តមអញ្ជើញវិលត្រឡប់មកមាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សហរដ្ឋមន្ត្រី-រដ្ឋមន្ត្រី-ប្រធានលេខាធិការដ្ឋានក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល និងសាមីខ្លួនដូចក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី ស្តីទី

ហ៊ុន សែន

កន្លែងទទួល :

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការ សម្របសម្រួល និងគ្រប់គ្រងគំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើការិយាល័យ [illegible]

សម្រេច

ប្រការ ១ បង្កើតគណៈកម្មការសម្របសម្រួល [illegible] គំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ ភ្នំពេញ [illegible] ដែលមានសមាសភាព [illegible] ដូចតទៅ៖

1. [illegible] ក្រសួងសាធារណការ និងដឹកជញ្ជូន [illegible]
2. [illegible] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ [illegible]
3. [illegible] ក្រសួងការពារជាតិ [illegible]
4. [illegible]
5. [illegible] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ [illegible]
6. [illegible]

ប្រការ ២ [illegible] ផ្លូវជាតិលេខ ៣ [illegible] ទៅដល់ទីរួមខេត្តកំពត [illegible] ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ។

ប្រការ ៣ [illegible] ត្រូវអនុវត្តសេចក្តីសម្រេចនេះ [illegible] ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ [illegible]

នាយករដ្ឋមន្ត្រី

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០៤-០៦៤ ប្រ.ក

ប្រកាស

ស្តីពី

រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ និងមុខងារ ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០២/០៣៩ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ៨៩៨-៣៨ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ៨៩៩-១៨៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងមុខងារភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមការអនុម័តរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី៣[illegible] ខែមេសា ឆ្នាំ[illegible]០៤

សម្រេច

ប្រការ ១. រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ និងកំណត់មុខងារ ភារកិច្ចរបស់ការិយាល័យ និងផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

ប្រការ ២. នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋាន ហើយមានមុខងារភារកិច្ចចំបងៗគឺ ៖

- សិក្សា ស្រាវជ្រាវ និងវិភាគស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងប្រទេស សម្រាប់ផ្តល់អនុសាសន៍ វាយតម្លៃ និងអភិវឌ្ឍគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា
- សិក្សា ស្រាវជ្រាវ និងវិភាគស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រៅប្រទេស សម្រាប់ផ្តល់អនុសាសន៍ វាយតម្លៃ និងអភិវឌ្ឍគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងទទួលបន្ទុកការងារសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ
- ប្រមូល តម្លើង និងវិភាគស្ថិតិជញ្ជីងទូទាត់ និងស្ថិតិរូបិយវត្ថុ
- ប្រមូល ចងក្រង និងបោះពុម្ពផ្សាយ ស្ថិតិរូបិយវត្ថុ ស្ថិតិជញ្ជីងទូទាត់ សេដ្ឋកិច្ច របាយការណ៍អំពីសកម្មភាពការងាររបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រងបណ្ណាល័យ ។

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយ ឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

ប្រការ ៣. រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ត្រូវបានរៀបចំឱ្យមានការិយាល័យចំនួន ៥ នៅក្រោមឱវាទ ដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺ :

១ ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចក្នុងប្រទេស គ្រប់គ្រងផ្ទាល់ :
- ផ្នែកស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច
- ផ្នែកអភិវឌ្ឍគោលនយោបាយ
- ផ្នែកវាយតម្លៃគោលនយោបាយ ។

២ ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិ គ្រប់គ្រងផ្ទាល់ :
- ផ្នែកស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ចអន្តរជាតិ
- ផ្នែកស្រាវជ្រាវគោលនយោបាយអន្តរជាតិ
- ផ្នែកសហប្រតិបត្តិការអន្តរជាតិ ។

៣ ការិយាល័យផ្សព្វផ្សាយ និងបណ្ណាល័យ គ្រប់គ្រងផ្ទាល់ :
- ផ្នែកផ្សព្វផ្សាយ
- បណ្ណាល័យ
- ផ្នែករដ្ឋបាល ។

៤ ការិយាល័យស្ថិតិជញ្ជីងទូទាត់ គ្រប់គ្រងផ្ទាល់ :

- ផ្នែកប្រមូលនិងស្រាវជ្រាវទិន្នន័យ
- ផ្នែកចងក្រងស្ថិតិជញ្ជីងទូទាត់
- ផ្នែកសិក្សានិងវិភាគទិន្នន័យ ។

៥ ការិយាល័យស្ថិតិរូបិយវត្ថុ គ្រប់គ្រងផ្ទាល់ :

- ផ្នែកប្រមូលនិងស្រាវជ្រាវទិន្នន័យ
- ផ្នែកចងក្រងស្ថិតិរូបិយវត្ថុ
- ផ្នែកសិក្សានិងវិភាគទិន្នន័យ ។

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

ប្រការ ៤.- ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចក្នុងប្រទេសមានភារកិច្ច សិក្សា ស្រាវជ្រាវ វិភាគស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងប្រទេស ដើម្បីផ្ដល់យោបល់និងអនុសាសន៍ក្នុងការកែសម្រួលនិងផ្លាស់ប្ដូរគោលនយោបាយនិងកម្មវិធីដែលមានស្រាប់ ព្រមទាំងកំណត់គោលនយោបាយនិងកម្មវិធីថ្មី របស់ធនាគារជាតិនៃកម្ពុជា ស្របតាមការវិវត្តន៍នៃសភាពការណ៍សេដ្ឋកិច្ច រួមមានភារកិច្ចតាមផ្នែកដូចតទៅ :

១ ផ្នែកស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច :

- សិក្សា ស្រាវជ្រាវ និងវិភាគស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងប្រទេស សំរាប់ជាមូលដ្ឋានដល់ការអភិវឌ្ឍន៍គោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា
- សិក្សា ស្រាវជ្រាវពីលទ្ធភាពក្នុងការពង្រឹង និងពង្រីកវិស័យហិរញ្ញវត្ថុក្នុងប្រទេស ។

២ ផ្នែកអភិវឌ្ឍគោលនយោបាយ :

- ផ្ដល់អនុសាសន៍សំរាប់ផ្លាស់ប្ដូរគោលនយោបាយនិងកម្មវិធីដែលមានស្រាប់ និងសំរាប់កំណត់គោលនយោបាយនិងកម្មវិធីថ្មីរបស់ធនាគារជាតិនៃកម្ពុជា
- សហការជាមួយស្ថាប័នដែលពាក់ព័ន្ធ ក្នុងការសិក្សានិងកំណត់គោលនយោបាយនិងកម្មវិធីថ្មីរបស់ធនាគារជាតិនៃកម្ពុជា
- រៀបចំឯកសារគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា ។

៣ ផ្នែកវាយតម្លៃគោលនយោបាយ :

វាយតម្លៃលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ និងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា ក្រោយការអនុវត្តន៍តាមគ្រាទីមួយៗ

- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ និងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា តាមគ្រាទីមួយៗ ។

ប្រការ ៥. ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិ មានភារកិច្ច សិក្សា ស្រាវជ្រាវ វិភាគ ស្ថានភាពសេដ្ឋកិច្ចក្រៅប្រទេស ដើម្បីប្រើប្រាស់ជាមូលដ្ឋានសំរាប់ផ្តល់យោបល់និងអនុសាសន៍ ក្នុងការកំណត់គោលនយោបាយនិងកម្មវិធី របស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងទទួលបន្ទុកការងារសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ រួមមានភារកិច្ចតាមផ្នែកដូចតទៅ :

១ ផ្នែកស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ចអន្តរជាតិ :

- សិក្សា ស្រាវជ្រាវ វិភាគស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិនិងក្នុងតំបន់ សំរាប់ជាមូលដ្ឋានដល់ការអភិវឌ្ឍន៍និងវាយតម្លៃគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា

វិភាគអំពីផលប៉ះពាល់នៃការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិ ទៅលើគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា ។

២ ផ្នែកស្រាវជ្រាវគោលនយោបាយអន្តរជាតិ :

ផ្តល់យោបល់ និងអនុសាសន៍ សំរាប់កែសម្រួលនិងផ្លាស់ប្តូរគោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនិងវិភាគអំពីស្ថានភាពសេដ្ឋកិច្ចអន្តរជាតិ

វាយតម្លៃការអនុវត្តន៍គោលនយោបាយនិងកម្មវិធីរបស់ធនាគារជាតិនៃកម្ពុជា តាមគ្រាទីមួយៗ ដោយគិតបញ្ចូលនូវផលប៉ះពាល់នៃការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិ ។

៣ ផ្នែកសហប្រតិបត្តិការអន្តរជាតិ :

ទំនាក់ទំនងនិងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នផ្សេងៗក្នុងតំបន់និងពិភពលោក ក្នុងវិស័យដែលពាក់ព័ន្ធនឹងមុខងាររបស់ធនាគារជាតិនៃកម្ពុជា រួមមានមូលនិធិរូបិយវត្ថុ

អន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី អាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក និងស្ថាប័ន ឬ អង្គការអន្តរជាតិផ្សេងទៀត ។

ប្រការ ៦.- ការិយាល័យផ្សព្វផ្សាយនិងបណ្ណាល័យ មានភារកិច្ចរៀបចំរបាយការណ៍ និងឯកសារផ្សេងៗ ផ្តល់ការគាំទ្រផ្នែករដ្ឋបាល គ្រប់គ្រងបណ្ណាល័យ រៀបចំ និងចែកផ្សាយការបោះពុម្ពផ្សាយផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១. ផ្នែកផ្សព្វផ្សាយ ៖

- រៀបចំចងក្រងព្រឹត្តិបត្រ ស្ថិតិរូបិយវត្ថុ ជញ្ជីងទូទាត់ និងសេដ្ឋកិច្ច អត្ថបទសិក្សា វិភាគ និងរបាយការណ៍ទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា សំរាប់បោះពុម្ពផ្សាយ
- ចែកផ្សាយព្រឹត្តិបត្រប្រចាំត្រីមាស របាយការណ៍ប្រចាំគ្រា និងអត្ថបទផ្សេងៗទៀត របស់ធនាគារជាតិនៃកម្ពុជា តាម Website ឬតាមការបោះពុម្ពផ្សាយ ។

២. បណ្ណាល័យ ៖

គ្រប់គ្រងបណ្ណាល័យឱ្យមានសណ្តាប់ធ្នាប់ ដោយរៀបចំសៀវភៅឬឯកសារតាមលំដាប់លំដោយ ដើម្បីងាយស្រួលរកឱ្យឃើញឆាប់រហ័ស និងការពារកុំឱ្យបាត់បង់ ។

៣. ផ្នែករដ្ឋបាល ៖

- ធ្វើការងាររដ្ឋបាលរបស់នាយកដ្ឋាន ។

ប្រការ ៧.- ការិយាល័យស្ថិតិជញ្ជីងទូទាត់ មានភារកិច្ចប្រមូលទិន្នន័យដើម្បីតម្លើងស្ថិតិជញ្ជីងទូទាត់និងស្ថានភាពវិនិយោគអន្តរជាតិ វិភាគទិន្នន័យ រៀបចំការអង្កេតថ្មីៗអំពីពត៌មានដែលពាក់ព័ន្ធនឹងស្ថិតិជញ្ជីងទូទាត់ រួមមានភារកិច្ចតាមផ្នែកដូចតទៅ ៖

១. ផ្នែកប្រមូលនិងស្រាវជ្រាវទិន្នន័យ ៖

- ប្រមូលនិងស្រាវជ្រាវទិន្នន័យជាប្រចាំពីប្រភពដែលពាក់ព័ន្ធ និងរៀបចំការអង្កេតថ្មីៗទៀត ដើម្បីប្រមូលពត៌មានបន្ថែម
- ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យតាមរបាយការណ៍ស្ថិតិ ដែលទទួលបានពីប្រភពផ្សេងៗ ។

២. ផ្នែកចងក្រងស្ថិតិជញ្ជីងទូទាត់ ៖

- តម្លើងស្ថិតិជញ្ជីងទូទាត់និងស្ថានភាពវិនិយោគអន្តរជាតិ ប្រចាំគ្រា សំរាប់ប្រទេសកម្ពុជា ។

៣. ផ្នែកសិក្សានិងវិភាគទិន្នន័យ :

- សិក្សា និងវិភាគទិន្នន័យ សំរាប់ចងក្រងអត្ថបទវិភាគស្ថិតិជញ្ជីងទូទាត់ ។

ប្រការ ៨. ការិយាល័យស្ថិតិរូបិយវត្ថុមានភារកិច្ចប្រមូលទិន្នន័យពីនាយកដ្ឋានដែលពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រភពផ្សេងៗទៀត ដើម្បីតម្លើងស្ថិតិរូបិយវត្ថុ រួមមានភារកិច្ចតាមផ្នែកដូចតទៅ :

១. ផ្នែកប្រមូលនិងស្រាវជ្រាវទិន្នន័យ :

- ប្រមូល ស្រាវជ្រាវ និងផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន
- តាមដានសកម្មភាពទទួលប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ដែលមិនទាន់ត្រូវបានបញ្ចូលក្នុងស្ថិតិរូបិយវត្ថុ និងពិនិត្យលទ្ធភាពដាក់បញ្ចូលស្ថាប័នទាំងនេះទៅក្នុងស្ថិតិរូបិយវត្ថុ។

២. ផ្នែកចងក្រងស្ថិតិរូបិយវត្ថុ :

- តម្លើងតារាងស្ថានភាពរូបិយវត្ថុនិងហិរញ្ញវត្ថុ និងតារាងស្ថិតិចាំបាច់ផ្សេងៗទៀត ។

៣. ផ្នែកសិក្សា និងវិភាគទិន្នន័យ :

- សិក្សា និងវិភាគទិន្នន័យសម្រាប់ចងក្រងអត្ថបទស្ថិតិរូបិយវត្ថុ
- ផ្តល់ពតិមានចាំបាច់សម្រាប់ការវិភាគទិន្នន័យស្ថិតិរូបិយវត្ថុ ។

ប្រការ ៩. ក្រៅពីភារកិច្ចដែលមានចែងនៅរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦ និងមាត្រា៧១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

ប្រការ ១០. រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ និងប្រកាសលេខ ធ៨-៩៩-១៤៧ ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១១. អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមី ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១២.- ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មេសា ឆ្នាំ២០០៤

ទេសាភិបាល

ជា.ចាន់តូ

កន្លែងទទួល:

- ដូចប្រការ១១

  "ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ

....

ចម្លងជូន :

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាបជាពត៌មាន"

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ

ឧបសម្ព័ន្ធលេខ
ស្តីពី
រចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ
(ឧបសម្ព័ន្ធនៃប្រកាសលេខ..............ប្រកាសថ្ងៃទី.......ខែមេសា ឆ្នាំ២០០៤)